**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# កិច្ចព្រមព្រៀង
## រវាង
## រោងចក្រ ខេវីធី អ៊ីអិមប៊ី បេស (ខេមបូឌា) ឯ.ក
## ជាមួយប្រតិភូបុគ្គលិក និងកម្មករនិយោជិតទាំងអស់

នៅថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២៤ វេលាម៉ោង ៨:០០ព្រឹក នៅសហគ្រាស **ខេវីធី អ៊ីអិមប៊ី បេស** (ខេមបូឌា) ឯ.ក មានកិច្ចប្រជុំមួយរវាងប្រធានរដ្ឋបាល និងប្រតិភូបុគ្គលិក ជំនួសឲ្យកម្មករនិយោជិតសរុបចំនួន ២៥នាក់។ ក្នុងអង្គប្រជុំនេះ ប្រធានរដ្ឋបាលបានជូនដំណឹងដល់ប្រតិភូបុគ្គលិក ស្តីពីស្ថានភាពបច្ចុប្បន្ននៃរោងចក្រដែល មិនមានការបញ្ជាទិញពីអតិថិជន នាំឱ្យមានផលប៉ះពាល់រោងចក្រ។ ហេតុដូចនេះរោងចក្រសម្រេចព្យួរកិច្ចសន្យាការងារកម្មករនិយោជិតចំនួន ០៦នាក់ (ស្រី០៤នាក់) បន្ថែមក្នុងចំណោមកម្មករនិយោជិតសរុបចំនួន ២៥នាក់ (ស្រី១៧នាក់) រយៈពេល៦១ថ្ងៃ ដោយគិតចាប់ពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៤។ ក្នុងកំឡុងពេលព្យួរកិច្ចសន្យាការងារនេះកម្មករនិយោជិតបានឯកភាពទទួលយកការផ្តល់ជូនរបស់រោងចក្រនូវប្រាក់ឧបត្ថម្ភចំនួន ៦០ដុល្លា (60$) ក្នុងនោះ៖

- ចំនួន៣០ដុល្លា ពីថ្ងៃទី០១ ដល់ថ្ងៃទី៣០ ខែមេសា
- ចំនួន៣០ដុល្លា ពីថ្ងៃទី០១ ដល់ថ្ងៃទី៣១ ខែឧសភា

ប្រាក់ឧបត្ថម្ភក្នុងកំឡុងពេលព្យួរកិច្ចសន្យាការងារនេះនឹងបើកជូនកម្មករនិយោជិតរៀងរាល់ថ្ងៃទី១០នៃខែបន្ទាប់។

អង្គប្រជុំបានបញ្ចប់នៅវេលាម៉ោង ៨:៥០នាទីព្រឹកនា ថ្ងៃខែឆ្នាំដដែលប្រកបដោយបរិយាកាសរីករាយ និងស្និទ្ធស្នាល ក្រោមស្មារតីទទួលខុសត្រូវខ្ពស់ និងយោគយល់សហការគ្នាយ៉ាងរលូន។

រាជធានីភ្នំពេញ, ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២៤

ហត្ថលេខា និងត្រាក្រុមហ៊ុន

**នាយកក្រុមហ៊ុន**

KVT EMB BEST (CAMBODIA) CO., LTD.
KINGDOM OF CAMBODIA

ស្នាមមេដៃប្រតិភូបុគ្គលិក និងកម្មករនិយោជិត